# ព្រះរាជក្រម

នស/រកម/១១១៧/០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ចូល លេខ...
ថ្ងៃទី... ឆ្នាំ... ម៉ោង...
បញ្ជូនទៅ...

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# ឧបាស្រ័យពាណិជ្ជកម្ម

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.**_គោលបំណង

ច្បាប់នេះមានគោលបំណងការពារនិងដោះស្រាយផលប៉ះពាល់ជាអវិជ្ជមានចំពោះឧស្សាហកម្មកម្ពុជាបណ្តាលមកពីការធ្វើពាណិជ្ជកម្មនាំចូលដោយមិនស្មោះត្រង់និងការនាំចូលដោយគំហុក ដោយប្រើប្រាស់វិធានការឧបាស្រ័យពាណិជ្ជកម្ម អនុលោមតាមកិច្ចព្រមព្រៀងពាក់ព័ន្ធរបស់អង្គការពាណិជ្ជកម្មពិភពលោក ។

**មាត្រា ២** ._គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីគោលការណ៍ យន្តការ នីតិវិធី និងវិធានទាក់ទងនឹងឧបាស្រ័យពាណិជ្ជកម្ម។

**មាត្រា ៣** ._វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការលក់បង្ខូចថ្លៃ ការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវ និងវិធានការ ការពារទាក់ទងនឹងការធ្វើពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមតាមកិច្ចព្រមព្រៀងពាក់ព័ន្ធរបស់អង្គការពាណិជ្ជកម្មពិភពលោក ។

**មាត្រា ៤** ._និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

# ជំពូកទី ២
# គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម

**មាត្រា ៥** ._គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម

ត្រូវបានបង្កើតគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញភារកិច្ចនានាពាក់ព័ន្ធនឹងឧបាស្រ័យពាណិជ្ជកម្ម ស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៣
# នីតិវិធីឧបាស្រ័យពាណិជ្ជកម្ម

## ផ្នែកទី ១
## វិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ

**មាត្រា ៦** .-អត្តសញ្ញាណកម្មនៃការលក់បង្ខូចថ្លៃ

ផលិតផលទាំងឡាយណាដែលស្ថិតក្រោមការស៊ើបអង្កេត ហើយកំពុងចរាចរក្នុងគោលដៅពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយលក់ក្នុងថ្លៃដែលទាបជាងតម្លៃធម្មតានៅក្នុងប្រទេសប្រភពដើម ត្រូវចាត់ទុកថាជាផលិតផលដែលលក់បង្ខូចថ្លៃ ។

**មាត្រា ៧** .-តម្លៃធម្មតាផ្អែកលើថ្លៃនៅក្នុងប្រទេសនាំចេញ ឬប្រទេសប្រភពដើម

គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់តម្លៃធម្មតានៃផលិតផលក្រោមការស៊ើបអង្កេត ដោយផ្អែកលើមូលដ្ឋានថ្លៃប្រៀបធៀបដែលបានបង់ ឬដែលត្រូវបង់ក្នុងការធ្វើពាណិជ្ជកម្មធម្មតាសម្រាប់ការលក់ផលិតផលដូចគ្នានោះដល់ដៃអ្នកប្រើប្រាស់នៅក្នុងប្រទេសនាំចេញ ។

**មាត្រា ៨** .-តម្លៃធម្មតាផ្អែកលើថ្លៃនាំចេញទៅប្រទេសទី ៣ ឬតម្លៃដែលបានកសាង

នៅពេលដែលគ្មានការលក់នូវផលិតផលដូចគ្នានៅក្នុងទីផ្សារក្នុងស្រុកនៃប្រទេសនាំចេញឬនៅពេលដែលមានការលក់ដែរ តែមិនអាចយកជាមូលដ្ឋានមកប្រៀបធៀបបានដោយហេតុផលស្ថានភាពទីផ្សារ ឬដោយសារទំហំនៃការលក់មានកម្រិតតិចតួចក្នុងប្រទេសនាំចេញ នោះគណៈកម្មាធិការ-ជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់តម្លៃធម្មតានៃផលិតផលក្រោមការស៊ើបអង្កេត ផ្អែកលើមូលដ្ឋានណាមួយក្នុងកថាខណ្ឌ (១) ឬ (២) ដូចខាងក្រោម៖

១- ផ្អែកលើថ្លៃប្រៀបធៀបនៃផលិតផលដូចគ្នា នៅពេលនាំចេញពីប្រទេសប្រភពដើមចូលទៅកាន់ប្រទេសទីបី ដែលបង្ហាញថាថ្លៃផលិតផលដូចគ្នានោះអាចជាថ្លៃតំណាងដើម្បីយកធ្វើជាមូលដ្ឋាន ឬ

២- ផ្អែកលើចំណាយផលិតកម្មនៅក្នុងប្រទេសប្រភពដើម បូកនឹងចំណាយរដ្ឋបាលសមស្រប ចំណាយលើការលក់ និងចំណាយផ្សេងៗទៀត រួមទាំងប្រាក់ចំណេញ ។

**មាត្រា ៩** .-ថ្លៃនាំចេញ

ថ្លៃនាំចេញត្រូវបានកំណត់ដូចខាងក្រោម៖

ក-ថ្លៃនាំចេញ គឺថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដសម្រាប់ផលិតផលក្រោមការស៊ើបអង្កេត នៅពេលដែលបានលក់សម្រាប់នាំចេញពីប្រទេសនាំចេញមកកម្ពុជា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ខ-ក្នុងករណីដែលគ្មានថ្លៃនាំចេញឬនៅពេលដែលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម យល់ឃើញថា ថ្លៃនាំចេញមិនអាចជឿជាក់បាន ដោយសារការទិញ លក់ទំនិញ ធ្វើឡើងតាមរយៈ សមាគមឬជាលក្ខណៈបំពេញខាតរវាងអ្នកនាំចេញនិងអ្នកនាំចូលឬភាគីទីបីណាមួយ ដូច្នេះ៖

១-ថ្លៃនាំចេញអាចត្រូវបង្កើតឡើងលើមូលដ្ឋាននៃថ្លៃដែលផលិតផលនាំចូល ត្រូវបានលក់បន្តលើកដំបូងទៅឲ្យអ្នកទិញឯករាជ្យណាមួយ ឬ

២-គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មអាចកំណត់ថ្លៃនាំចេញ ដោយផ្អែកលមូលដ្ឋានសមស្របណាមួយ ប្រសិនបើផលិតផលមិនទាន់បានលក់បន្តទៅឲ្យអ្នកទិញឯករាជ្យណាមួយ ឬត្រូវបានលក់បន្តដោយបានកែច្នៃខុសពីស្ថានភាពដើមនៅពេលនាំចូល ។

គ-នៅពេលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម កំណត់តម្លៃធម្មតាដោយផ្អែកលើមូលដ្ឋាននៃប្រទេសប្រភពដើម ថ្លៃនាំចេញត្រូវតែជាថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដសម្រាប់ផលិតផលក្រោមការស៊ើបអង្កេត នៅពេលលក់សម្រាប់នាំចេញនៅក្នុងប្រទេសប្រភពដើមនោះ ។

**មាត្រា ១០** ._ការកែតម្រូវតម្លៃធម្មតានិងថ្លៃនាំចេញ

គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវធ្វើការប្រៀបធៀបដោយត្រឹមត្រូវរវាងថ្លៃនាំចេញនិងតម្លៃធម្មតា ។ ការប្រៀបធៀបនេះត្រូវតែធ្វើឡើងនៅទីតាំងដូចគ្នានៃការធ្វើពាណិជ្ជកម្មដែលជាធម្មតាគិតត្រឹមទ្វាររោងចក្រ និងការលក់ក្នុងពេលប្រហាក់ប្រហែលគ្នា។ ការកែតម្រូវសមហេតុផលត្រូវធ្វើឡើងក្នុងករណីមានភាពខុសគ្នា ដែលប៉ះពាល់ដល់ការប្រៀបធៀបតម្លៃ ។

**មាត្រា ១១** ._កម្រិតនៃការលក់បង្ខូចថ្លៃនីមួយៗ

គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់កម្រិតនៃការលក់បង្ខូចថ្លៃរបស់អ្នកនាំចេញ ឬផលិតករនីមួយៗដែលពាក់ព័ន្ធនឹងផលិតផលក្រោមការស៊ើបអង្កេត ។ ប៉ុន្តែគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម អាចកម្រិតការត្រួតពិនិត្យ និងលទ្ធផលនៃកម្រិតលក់បង្ខូចថ្លៃនីមួយៗដល់ចំនួនមួយដែលសមហេតុផល ចំពោះភាគីពាក់ព័ន្ធ ឬផលិតផលក្រោមការស៊ើបអង្កេត ។

**មាត្រា ១២** ._ការកំណត់ការខូចខាត

ការកំណត់ការខូចខាតសម្ភារៈណាមួយ ត្រូវតែធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងវិជ្ជមាន និងត្រូវមានការត្រួតពិនិត្យបែបសត្យានុម័តនូវចំណុចដូចខាងក្រោម ៖

ក- បរិមាណនៃការនាំចូលដោយបង្ខូចថ្លៃ

ខ- ផលប៉ះពាល់នៃការនាំចូលដោយបង្ខូចថ្លៃមកលើថ្លៃនៃផលិតផលដូចគ្នានៅទីផ្សារក្នុងស្រុក និង

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

គ- ការប៉ះពាល់ដែលជាផលវិបាកនៃការនាំចូលទាំងនេះ មកលើផលិតករក្នុងស្រុកនៃផលិតផលទាំងនោះ ។

**មាត្រា ១៣ .-** ការត្រួតពិនិត្យបរិមាណនៃការនាំចូលដោយបង្ខូចថ្លៃ និងផលប៉ះពាល់មកលើថ្លៃនៅកម្ពុជា

ក-ចំពោះបរិមាណនៃការនាំចូលដោយបង្ខូចថ្លៃ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវពិចារណាអំពីការកើតឡើងនូវកំណើនគួរឲ្យកត់សម្គាល់នៃការនាំចូលដោយបង្ខូចថ្លៃ ទោះជាក្នុងចំនួនដាច់ខាត ឬជាចំនួនប្រៀបធៀប ធៀបទៅនឹងបរិមាណនៃផលិតកម្ម ឬការប្រើប្រាស់នៅប្រទេសកម្ពុជា ។

ខ-ចំពោះផលប៉ះពាល់នៃការនាំចូលដោយបង្ខូចថ្លៃ មកលើថ្លៃនៅក្នុងទីផ្សារកម្ពុជាគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវពិចារណា បើសិនមានករណីដូចខាងក្រោម :

១- មានការធ្លាក់ថ្លៃគួរឲ្យកត់សំគាល់ដោយសារការនាំចូលដោយបង្ខូចថ្លៃ ធៀបនឹងថ្លៃនៃផលិតផលដូចគ្នា នៅទីផ្សារក្នុងស្រុក ឬ

២-ផលប៉ះពាល់នៃការនាំចូលទាំងនោះ បន្ទាបថ្លៃដល់កម្រិតមួយគួរឲ្យកត់សម្គាល់ ឬ អាចរារាំងមិនឲ្យមានការឡើងថ្លៃនៃផលិតផលដូចគ្នាក្នុងស្រុក ដល់កម្រិតថ្លៃទីផ្សារ ប្រសិនបើពុំមានការរារាំងនេះទេ ថ្លៃអាចកើនឡើងបាន ។

គ- ក្រៅពីកត្តាទាំងឡាយដែលបានបង្ហាញនៅក្នុងកថាខណ្ឌ "ក"និងកថាខណ្ឌ "ខ" នៃមាត្រានេះ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម អាចពិចារណាកត្តាផ្សេងទៀតដែលធ្វើឲ្យមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដល់ថ្លៃផលិតផលដូចគ្នាក្នុងស្រុក ។

**មាត្រា ១៤ .-** ការបូកបន្ថែម

នៅពេលការនាំចូលផលិតផលដូចគ្នាពីប្រទេសច្រើន ដែលជាកម្មវត្ថុនៃការស៊ើបអង្កេតទន្ទឹមពេលគ្នា ទាក់ទងនឹងការលក់បង្ខូចថ្លៃ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មអាចធ្វើការវាយតម្លៃរួមបញ្ចូលគ្នានូវផលប៉ះពាល់នៃការនាំចូលទាំងនោះដល់ឧស្សាហកម្មកម្ពុជា តែក្នុងករណីដែលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មពិនិត្យឃើញថា៖

ក- កម្រិតនៃការលក់បង្ខូចថ្លៃ ដែលបានរកឃើញទាក់ទងនឹងផលិតផលនាំចូលពីប្រទេសនីមួយៗ ដែលកំពុងស្ថិតក្រោមការស៊ើបអង្កេតមានច្រើនជាងកម្រិតអប្បបរមា ហើយបរិមាណនៃផលិតផលក្រោមការស៊ើបអង្កេតដែលនាំចូលពីប្រទេសនីមួយៗនោះ មិនមែនជាបរិមាណតិចតួច និង

ខ- ការវាយតម្លៃរួមបញ្ចូលគ្នាពីផលប៉ះពាល់នៃការនាំចូល មានលក្ខណៈសមស្របតាមលក្ខខណ្ឌនៃការប្រកួតប្រជែងរវាងការនាំចូល និងលក្ខខណ្ឌនៃការប្រកួតប្រជែងរវាងផលិតផលនាំចូលទាំងនោះនឹងផលិតផលដូចគ្នាក្នុងស្រុក ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ១៥ .-** ការត្រួតពិនិត្យផលប៉ះពាល់នៃការនាំចូលបង្ខូចថ្លៃមកលើឧស្សាហកម្មកម្ពុជា

ក- ការត្រួតពិនិត្យផលប៉ះពាល់នៃការនាំចូលបង្ខូចថ្លៃមកលើឧស្សាហកម្មដែលទទួលរងគ្រោះរបស់កម្ពុជា ត្រូវរួមបញ្ចូលនូវការវាយតម្លៃដោយគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មទៅលើកត្តា និងសន្ទស្សន៍សេដ្ឋកិច្ចទាំងឡាយដែលជះឥទ្ធិពលមកលើស្ថានភាពនៃឧស្សាហកម្ម ក្នុងនោះរួមមាន៖

១- ការធ្លាក់ចុះជាក់ស្តែង និងការធ្លាក់ចុះដែលអាចកើតមានឡើងពីការលក់ ផលចំណេញ ទិន្នផល ចំណែកទីផ្សារ ផលិតភាព ផលទទួលបានពីវិនិយោគ ឬការប្រើប្រាស់សមត្ថភាពផលិតកម្ម

២- កត្តាដែលជះឥទ្ធិពលដល់ថ្លៃក្នុងស្រុក

៣- ទំហំនៃកម្រិតលក់បង្ខូចថ្លៃ និង

៤- ផលប៉ះពាល់ជាក់ស្តែងអវិជ្ជមាននិងដែលអាចកើតមានមកលើលំហូរសាច់ប្រាក់ កំណើនសារពើភណ្ឌ ការងារប្រាក់ឈ្នួល លទ្ធភាពកៀរគរមូលធន ឬវិនិយោគទុន ។

មិនអាចផ្អែកលើកត្តាណាមួយក្នុងចំណោមកត្តាខាងលើ ធ្វើជាមូលដ្ឋានសម្រេចឡើយ ប៉ុន្តែកត្តាទាំងអស់រួមគ្នាអាចយកមកពិចារណាសម្រាប់ឈានទៅដល់ការសន្និដ្ឋានថា ការនាំចេញដោយបង្ខូចថ្លៃបានកើតឡើង ហើយកំពុងបណ្តាលឲ្យមានការខូចខាតសម្ភារៈដល់ឧស្សាហកម្មកម្ពុជា ។

ខ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវវាយតម្លៃពីផលប៉ះពាល់នៃការនាំចូលបង្ខូចថ្លៃ មកលើផលិតកម្មកម្ពុជាដែលផលិតនូវផលិតផលក្នុងស្រុកដូចគ្នា នៅពេលមានទិន្នន័យគ្រប់គ្រាន់សម្រាប់ធ្វើការញែកចេញពីគ្នានូវដំណើរការផលិតកម្ម ការលក់ និងផលចំណេញរបស់ផលិតករ។ ប្រសិនបើមិនអាចញែកបាន នោះគណៈកម្មាធិការជាតិ ត្រូវវាយតម្លៃពីផលប៉ះពាល់នៃការនាំចូលបង្ខូចថ្លៃមកលើផលិតកម្មនៃផលិតផលជាក្រុមតូចៗ ឬមកលើក្រុមផលិតផលផ្សេងទៀត ដោយរួមបញ្ចូលនូវផលិតផលក្នុងស្រុកដូចគ្នា តាមការដែលអាចរកព័ត៌មានចាំបាច់បាន ។

**មាត្រា ១៦ .-** ការគំរាមកំហែងនាំឲ្យខូចខាតសម្ភារៈ

ក- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់អំពីការគំរាមកំហែងនាំឲ្យខូចខាតសម្ភារៈដោយផ្អែកលើអង្គហេតុនានា ហើយមិនត្រូវផ្អែកលើអំណះអំណាងដោយគ្មានមូលដ្ឋាន ឬការប៉ាន់ស្មាននោះឡើយ។ នៅពេលមានការប្រែប្រួលណាមួយដែលអាចបង្កើតឲ្យមានការលក់បង្ខូចថ្លៃនាំឲ្យមានការខូចខាតសម្ភារៈ ត្រូវតែជាស្ថានភាពដែលអាចព្យាករបាននិងអាចកើតឡើង ។

ខ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់អំពីអត្ថិភាពនៃការគំរាមកំហែងនាំឲ្យមានការខូចខាតសម្ភារៈ ដោយផ្អែកលើកត្តាមួយចំនួនដូចខាងក្រោម៖

១- អត្រាកំណើនគួរឲ្យកត់សម្គាល់នៃការនាំចូលបង្ខូចថ្លៃមកក្នុងទីផ្សារប្រទេសកម្ពុជា ដែលបង្ហាញពីការនាំចូលកាន់តែច្រើនឡើង ។

២- កំណើនសមត្ថភាពផលិតរបស់អ្នកនាំចេញ បង្ហាញពីលទ្ធភាពនៃការកើនឡើងយ៉ាងខ្លាំងនៃការនាំចេញមកលក់បង្ខូចថ្លៃនៅទីផ្សារកម្ពុជា ។

៣- ការនាំចូលមកលក់តាមថ្លៃដែលនាំឲ្យថ្លៃផលិតផលដូចគ្នាក្នុងស្រុកធ្លាក់ចុះ ឬមិនកើនឡើង ហើយថ្លៃនាំចូលនោះបណ្ដាលឲ្យមានកំណើននៃសេចក្ដីត្រូវការក្នុងការនាំចូលកាន់តែច្រើន។

៤- សារពើភណ្ឌនៃផលិតផលក្រោមការស៊ើបអង្កេត ។

គ- ប្រសិនបើមានការនាំចូលបង្ខូចថ្លៃ បានគំរាមគំហែងឲ្យមានការខូចខាតណាមួយគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវពិនិត្យ និងចាត់វិធានការដោយប្រុងប្រយ័ត្នបំផុត ។

**មាត្រា ១៧ .-** ទំនាក់ទំនងហេតុផល

ក- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវបង្ហាញឲ្យឃើញថាការនាំចូលបង្ខូចថ្លៃបណ្ដាលឲ្យមានការខូចខាតសម្ភារៈ តាមអត្ថន័យដូចមានចែងក្នុងច្បាប់នេះ។ ការបង្ហាញពីទំនាក់ទំនងហេតុផលរវាងការនាំចូលបង្ខូចថ្លៃ និងការខូចខាតដល់ឧស្សាហកម្មកម្ពុជា ត្រូវផ្អែកលើភស្តុតាងពាក់ព័ន្ធទាំងអស់ដែលគណៈកម្មាធិការប្រមូលបាន ។

ខ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវត្រួតពិនិត្យផងដែរចំពោះកត្តាផ្សេងទៀតក្រៅពីកត្តានាំចូលដោយបង្ខូចថ្លៃ ដែលកំពុងធ្វើឲ្យខូចខាតដល់ឧស្សាហកម្មកម្ពុជា ហើយការខូចខាតដែលបង្កដោយកត្តាដទៃទៀតទាំងនោះ មិនត្រូវយកមកដាក់បន្ទុកថាជាការនាំចូលបង្ខូចថ្លៃឡើយ ។ កត្តាផ្សេងៗទាំងនោះ រួមមាន ៖

១- បរិមាណ និងថ្លៃនាំចូល មិនត្រូវបានលក់ក្នុងថ្លៃដែលនាំឲ្យបង្ខូចថ្លៃ ។

២- ការថយចុះនូវតម្រូវការ ឬការផ្លាស់ប្ដូរលំនាំនៃការប្រើប្រាស់ ។

៣- ការរឹតត្បិតពាណិជ្ជកម្មនៃផលិតករកម្ពុជា និងផលិតករបរទេស ។

៤- ការប្រកួតប្រជែងរវាងផលិតករបរទេស និងផលិតករក្នុងស្រុក ។

៥- ការអភិវឌ្ឍបច្ចេកវិទ្យា និង

៦- លទ្ធភាពនៃការនាំចេញពីបរទេស និងផលិតភាពរបស់ឧស្សាហកម្មកម្ពុជា ។

**មាត្រា ១៨ .-** នីតិវិធីផ្ដួចផ្ដើមការស៊ើបអង្កេត និងនីតិវិធីអនុវត្តការស៊ើបអង្កេត

ក- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មអាចចាប់ផ្ដើមស៊ើបអង្កេតអំពីការលក់បង្ខូចថ្លៃបាន នៅពេលមានពាក្យសុំជាលាយលក្ខណ៍អក្សរពីឧស្សាហកម្មកម្ពុជា ឬអាចចាប់ផ្ដើមស៊ើបអង្កេតដោយខ្លួនឯងបាន។ ពាក្យសុំឲ្យចាប់ផ្ដើមស៊ើបអង្កេត ត្រូវភ្ជាប់មកជាមួយនូវភស្តុតាងនៃការលក់បង្ខូចថ្លៃ ការខូចខាត និងទំនាក់ទំនងហេតុផល ដែលមានកំណត់នៅក្នុងច្បាប់នេះ។ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់អំពីនីតិវិធីចាប់ផ្ដើមស៊ើបអង្កេត រួមទាំងកំណត់ពីលក្ខណវិនិច្ឆ័យដែលត្រូវទទួលយកមកពិចារណានូវពាក្យស្នើសុំដោយផ្ទាល់ ឬតាងនាមឲ្យឧស្សាហកម្មកម្ពុជា ។ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម មិនត្រូវផ្សាយជាសាធារណៈ ពីការស៊ើបអង្កេតនៃការលក់បង្ខូច

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ថ្លៃ មុនពេលចាប់ផ្តើមស៊ើបអង្កេតឡើយ ប៉ុន្តែត្រូវផ្សព្វផ្សាយភ្លាមនូវសេចក្តីជូនដំណឹងអំពីការសម្រេចចាប់ផ្តើមស៊ើបអង្កេត ។

ខ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវចេញសេចក្តីសម្រេចបឋមនិងចុងក្រោយអំពីការលក់បង្ខូចថ្លៃ និងការខូចខាត ។ បន្ទាប់ពីមានសេចក្តីសម្រេចបឋមថា មានការលក់បង្ខូចថ្លៃ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម អាចចាត់វិធានការបណ្តោះអាសន្នបាន ប្រសិនបើគណៈ-កម្មាធិការជាតិអាចកំណត់បានថា វិធានការនេះត្រូវការជាចាំបាច់ដើម្បីទប់ស្កាត់ការខូចខាតដែលកើតមានក្នុងកំលុងពេលស៊ើបអង្កេត ។

គ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់គោលការណ៍ និងលក្ខខណ្ឌដែលទាក់ទងនឹងការទទួលយកកិច្ចព្រមព្រៀងកែសម្រួលថ្លៃដោយស្ម័គ្រចិត្ត ក្នុងករណីដែលអ្នកនាំចេញយល់ព្រមធ្វើការកែសម្រួលថ្លៃលក់ផលិតផល ដើម្បីលុបបំបាត់នូវការលក់បង្ខូចថ្លៃ ។ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់ពីនីតិវិធីសម្រាប់ដោះស្រាយ នៅពេលមានការរំលោភកិច្ចព្រមព្រៀងកែសម្រួលថ្លៃ។ ការស៊ើបអង្កេត អាចត្រូវបានបញ្ឈប់នៅពេលមានការដកពាក្យសុំស៊ើបអង្កេត ឬនៅពេលដែលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មពិនិត្យឃើញ និងសម្រេចបានថាគ្មានភស្តុតាងគ្រប់គ្រាន់អំពីការលក់បង្ខូចថ្លៃ ឬការខូចខាត ដែលអាចដំណើរការសំណុំរឿងបន្តទៀតបាន ។ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយនូវសេចក្តីជូនដំណឹងអំពីការសម្រេចបញ្ឈប់ការស៊ើបអង្កេត ។

ឃ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់នីតិវិធីសម្រាប់រក្សាការសម្ងាត់នូវព័ត៌មានទាំងឡាយណាដែលបានដាក់ជូនគណៈកម្មាធិការដោយភាគីពាក់ព័ន្ធ ហើយដែលបានស្នើសុំរក្សាការសម្ងាត់ ។ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវរក្សាទុកនូវឯកសារសាធារណៈដែលមានផ្ទុកនូវព័ត៌មានមិនសម្ងាត់ដែលទទួលបានក្នុងពេលស៊ើបអង្កេត ។ នៅពេលមានសំណើគណៈ-កម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវរៀបចំសវនាការសាធារណៈដែលភាគីពាក់ព័ន្ធទាំងអស់អាចចូលរួមបាន ។ ភាគីពាក់ព័ន្ធទាំងអស់ ក៏ដូចជាតំណាងឧស្សាហកម្មកម្ពុជាដែលប្រើប្រាស់ផលិតផលនោះ និងអ្នកប្រើប្រាស់ដទៃទៀត ក៏អាចបញ្ចេញយោបល់ជាលាយលក្ខណ៍អក្សរក្នុងកំលុងពេលស៊ើបអង្កេត និងសវនាការផងដែរ ។

ង- នីតិវិធីលម្អិតទាក់ទងនឹងការផ្តួចផ្តើមនិងការស៊ើបអង្កេត ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៩ .-** ការស៊ើបអង្កេតដែលនាំឲ្យមានការកំណត់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ

នៅពេលដែលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មបញ្ចប់ការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចថ្លៃ ដោយចេញនូវសេចក្តីសម្រេចថា មានការខូចខាត និងមានការលក់បង្ខូចថ្លៃ នោះវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃនឹងត្រូវបានអនុវត្តស្របតាមច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា២០ ._** ផលប្រយោជន៍សាធារណៈរបស់កម្ពុជា និងវិធានពន្ធទាបជាង

ក- ចំនួនប្រាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ មិនត្រូវលើសពីកម្រិតលក់បង្ខូចថ្លៃ ដែលមានកំណត់ក្នុងច្បាប់នេះ ។ នៅពេលដែលពិនិត្យឃើញថា លក្ខខណ្ឌតម្រូវទាំងអស់សម្រាប់ការកំណត់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃត្រូវបានបំពេញសព្វគ្រប់ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវផ្ទៀងផ្ទាត់ថា ការដាក់ចេញនូវវិធានការនេះ ពិតជាបម្រើឲ្យផលប្រយោជន៍របស់កម្ពុជា ។ ការគិតគូរអំពីផលប្រយោជន៍របស់កម្ពុជា ត្រូវរួមបញ្ចូលនូវ ៖

- ផលប្រយោជន៍ឧស្សាហកម្មកម្ពុជាដែលពាក់ព័ន្ធ
- ស្ថានភាពប្រកួតប្រជែងក្នុងស្រុកចំពោះផលិតផលស្ថិតក្រោមការស៊ើបអង្កេត
- ផលប្រយោជន៍អ្នកប្រើប្រាស់ក្នុងគោលដៅឧស្សាហកម្ម និង
- ផលប្រយោជន៍របស់អ្នកប្រើប្រាស់ចុងក្រោយ ។

ក្នុងករណីការកំណត់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃបម្រើឲ្យផលប្រយោជន៍សាធារណៈ នោះអត្រាពន្ធនេះ ត្រូវកំណត់ទាបជាងកម្រិតពន្ធលក់បង្ខូចថ្លៃ ។

ខ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវពិនិត្យមើលផងដែរអំពីពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃដែលកំណត់ទាបជាងកម្រិតពេញលេញនៃការលក់បង្ខូចថ្លៃ ពិតជាគ្រប់គ្រាន់អាចនឹងលុបបំបាត់ការខូចខាតដល់ឧស្សាហកម្មកម្ពុជា ។ នៅពេលដែលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម កំណត់បានថាអត្រាពន្ធនេះល្មមគ្រប់គ្រាន់នឹងលុបបំបាត់ការខូចខាតបាន នោះចំនួនប្រាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃចុងក្រោយដែលត្រូវដាក់ មិនត្រូវលើសពីអត្រាពន្ធទាបជាងនេះឡើយ ។

**មាត្រា ២១ ._** ការកំណត់ពន្ធនិងការប្រមូលប្រាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ

ក- ប្រាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ត្រូវប្រមូលដោយគិតតាមអត្រា ឬគិតតាមតម្លៃឯកតាដែលកំណត់បន្ថែមទៅលើអត្រាពន្ធនាំចូលចំពោះផលិតផលនាំចូលនោះ ។ ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃនេះត្រូវប្រមូលដោយរដ្ឋបាលគយកម្ពុជា ក្នុងបរិមាណសមស្របតាមករណីនីមួយៗ ដោយផ្អែកលើមូលដ្ឋានមិនរើសអើងចំពោះការនាំចូលផលិតផលពីគ្រប់ប្រភពដែលបានរកឃើញថាមានការលក់បង្ខូចថ្លៃ និងដែលបង្កឲ្យមានការខូចខាត លើកលែងតែការនាំចូលដែលការកែសម្រួលថ្លៃត្រូវបានទទួលយករួចហើយ ស្របតាមលក្ខខណ្ឌនៃច្បាប់នេះ ។

ខ-នៅក្នុងការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចថ្លៃ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់អត្រាពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃដោយឡែកៗ ចំពោះអ្នកនាំចេញ ឬផលិតករនៃផលិតផលនាំចូលដែលមានការលក់បង្ខូចថ្លៃ ។ ក្នុងករណីដែលផលិតករទាំងនោះ មានចំនួនច្រើនពេក ដែលអាចបង្កើតជាឧបសគ្គមិនឲ្យបញ្ចប់ការស៊ើបអង្កេតបានទាន់ពេលវេលា គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម អាចកំណត់អត្រាពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃជារួមបាន ។

គ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវបង្វិលសងវិញនូវប្រាក់ពន្ធដែលបានបង់លើសកម្រិតលក់បង្ខូចថ្លៃ និងព្យួរជាបណ្ដោះអាសន្ននូវការអនុវត្តវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ នៅពេលដែលលក្ខខណ្ឌទីផ្សារមានការប្រែប្រួល និងការអនុវត្តពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃមិនបម្រើឲ្យផលប្រយោជន៍របស់កម្ពុជា ។

**មាត្រា ២២ .-** ការអនុវត្តដោយមានអានុភាពប្រតិសកម្ម

ពន្ធស្ពាពរប្រឆាំងនឹងការលក់បង្ខូចថ្លៃត្រូវប្រមូលយកពីផលិតផលស្ថិតក្រោមការស៊ើបអង្កេត ដែលបាននាំចូលមកលក់សម្រាប់រយៈពេលមិនលើសពី ៩០(កៅសិប)ថ្ងៃ មុនកាលបរិច្ឆេទនៃការអនុវត្តវិធានការបណ្ដោះអាសន្ន ប៉ុន្តែមិនត្រូវប្រមូលពីផលិតផលដែលបាននាំចូល មុនកាលបរិច្ឆេទផ្ដួចផ្ដើមការស៊ើបអង្កេតឡើយ ក្នុងករណីដែលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មកំណត់បានថា ផលិតផលលក់បង្ខូចថ្លៃនោះ ៖

ក- ធ្លាប់មានប្រវត្តិលក់បង្ខូចថ្លៃដែលបណ្ដាលឲ្យមានការខូចខាត ឬដែលអ្នកនាំចូលធ្លាប់បានដឹង ឬអាចដឹងថាអ្នកនាំចេញយកមកលក់បង្ខូចថ្លៃដែលបណ្ដាលឲ្យមានការខូចខាត និង

ខ-ការខូចខាតបណ្ដាលមកពីការនាំចូលលក់បង្ខូចថ្លៃក្នុងទំហំច្រើនសន្ធឹកសន្ធាប់ក្នុងរយៈពេលខ្លី ព្រមទាំងផ្អែកតាមកាលៈទេសៈផ្សេងទៀត ដូចជាការបង្កើនយ៉ាងគំហុកនូវបរិមាណសារពើ-ភណ្ឌនៃផលិតផលនោះ ដើម្បីគេចវេះពីការយកពន្ធស្ពាពរដោយអាជ្ញាធរ ។ ក្នុងករណីនេះគណៈកម្មាធិការត្រូវផ្ដល់ឱកាសដល់អ្នកនាំចូលពាក់ព័ន្ធទាំងនោះ ធ្វើការបកស្រាយពីហេតុផលនៃការបង្កើនបរិមាណសារពើភណ្ឌដ៏គំហុកនោះ ។

**មាត្រា ២៣ .-** ការប្រមូលប្រាក់ពន្ធស្ពាពរលើទំនិញលក់បង្ខូចថ្លៃក្នុងកំលុងពេលអនុវត្តវិធានការពន្ធបណ្ដោះអាសន្ន

ក-ប្រាក់ពន្ធស្ពាពរប្រឆាំងនឹងការលក់បង្ខូចថ្លៃអាចប្រមូលដោយប្រតិសកម្មបាន សម្រាប់កំលុងពេលដែលវិធានការបណ្ដោះអាសន្នបានអនុវត្តរួចរាល់ ក្នុងករណីដែល ៖

១- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មបានចេញសេចក្ដីសម្រេចចុងក្រោយអំពីការខូចខាត ឬ

២- សេចក្ដីសម្រេចចុងក្រោយផ្អែកលើហេតុផលថា ក្នុងពេលអនុវត្តវិធានការបណ្ដោះអាសន្ន ឥទ្ធិពលនៃការនាំចូលផលិតផលលក់បង្ខូចថ្លៃនោះ នៅតែបង្កឲ្យមានការខូចខាតសម្ភារៈ ។

ខ-ប្រសិនបើសេចក្ដីសម្រេចចុងក្រោយអំពីការខូចខាត រកឃើញត្រឹមតែធ្វើឲ្យមានការយឺតយ៉ាវក្នុងការបង្កើតឧស្សាហកម្មណាមួយនោះ ការយកពន្ធស្ពាពរប្រឆាំងនឹងការលក់បង្ខូចថ្លៃ មិនត្រូវអនុវត្តដោយមានអានុភាពប្រតិសកម្មឡើយ ។

គ- ក្នុងករណីដែលពន្ធស្ពាពរប្រឆាំងនឹងការលក់បង្ខូចថ្លៃ មានបរិមាណច្រើនជាងបរិមាណពន្ធបណ្ដោះអាសន្នដែលបានបង់ ឬបរិមាណទឹកប្រាក់ប៉ាន់ស្មានសម្រាប់គោលបំណងនិមុត្តិធានា ទឹកប្រាក់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ដែលខុសគ្នានោះពុំចាំបាច់ត្រូវទារឡើយ ។ ក្នុងករណីពន្ធស្ថាពរមានបរិមាណតិចជាងបរិមាណពន្ធបណ្តោះអាសន្នដែលបានបង់រួចហើយ ឬបរិមាណទឹកប្រាក់ប៉ាន់ស្មានសម្រាប់គោលបំណងនិមុត្តិធានា ទឹកប្រាក់ដែលខុសគ្នានោះត្រូវបង្វិលសងទៅអ្នកនាំចូលវិញ ឬពន្ធស្ថាពរប្រឆាំងនឹងការលក់បង្ខូចថ្លៃនោះត្រូវគណនាឡើងវិញ ។

ឃ- ក្រៅពីការកំណត់ក្នុងកថាខណ្ឌ "ក" ខាងលើ ប្រសិនបើគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មចេញសេចក្តីសម្រេចអំពីការគំរាមកំហែងឲ្យមានការខូចខាត ឬការយឺតយ៉ាវក្នុងការបង្កើតឧស្សាហកម្មនោះ ប្រាក់ពន្ធស្ថាពរប្រឆាំងនឹងការលក់បង្ខូចថ្លៃតម្រូវឲ្យបង់ ត្រូវគិតចាប់ពីត្រឹមពេលមានសេចក្តីសម្រេចអំពីការគំរាមកំហែងឲ្យមានការខូចខាត ឬការយឺតយ៉ាវក្នុងការបង្កើតឧស្សាហកម្មនោះតែប៉ុណ្ណោះ ។ និមុត្តិធានាដែលបានផ្តល់ឲ្យក្នុងកំលុងពេលអនុវត្តវិធានការបណ្តោះអាសន្ននោះ ត្រូវបង្វិលសងទៅអ្នកនាំចេញវិញ មិនឲ្យយឺតជាង ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

ង- ករណីដែលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ចេញសេចក្តីសម្រេចចុងក្រោយជាអវិជ្ជមាន និមុត្តិធានាដែលបានផ្តល់ឲ្យក្នុងកំលុងពេលអនុវត្តវិធានការបណ្តោះអាសន្ននោះ ត្រូវបង្វិលសងទៅអ្នកនាំចេញវិញ មិនឲ្យយឺតជាង ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ ។

**មាត្រា ២៤ .-** គោលការណ៍ទាក់ទងនឹងរយៈពេល និងការត្រួតពិនិត្យឡើងវិញនូវពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងការទទួលយកថ្លៃកែសម្រួល

ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃត្រូវមានប្រសិទ្ធភាពអនុវត្ត តែក្នុងរយៈពេលដែលអាចធ្វើទៅបានដូចមានកំណត់ក្នុងច្បាប់នេះ និងត្រឹមកម្រិតដែលចាំបាច់សម្រាប់ទប់ទល់នឹងការលក់បង្ខូចថ្លៃដែលនាំឲ្យមានការខូចខាតដល់ឧស្សាហកម្មកម្ពុជាតែប៉ុណ្ណោះ ។

**មាត្រា ២៥ .-** ការត្រួតពិនិត្យឡើងវិញ

ពន្ធស្ថាពរប្រឆាំងនឹងការលក់បង្ខូចថ្លៃត្រូវបញ្ចប់ក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពន្ធស្ថាពរនោះ ឬគិតចាប់ពីកាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញចុងក្រោយបំផុតទាក់ទងនឹងការលក់បង្ខូចថ្លៃ និងការខូចខាត ។ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃផុតសុពលភាពនៃវិធានការពន្ធស្ថាពរប្រឆាំងនឹងការលក់បង្ខូចថ្លៃ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីការផុតសុពលភាពនៅក្នុងព្រឹត្តិបត្រព័ត៌មានផ្លូវការ ។ វិធានការពន្ធស្ថាពរអាចមិនផុតសុពលភាពទេ ប្រសិនបើគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មកំណត់បានថាការផុតសុពលភាពនៃការអនុវត្តពន្ធនោះអាចនឹងនាំឲ្យមានការបន្ត ឬការកើតឡើងវិញនូវការលក់បង្ខូចថ្លៃ និងការខូចខាត ផ្អែកតាមការត្រួតពិនិត្យឡើងវិញដែលបានផ្តួចផ្តើមធ្វើនៅមុនថ្ងៃផុតសុពលភាពនោះ ទោះបីជាធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ឬតាមការស្នើសុំត្រឹមត្រូវជាបន្តបន្ទាប់ ដែលបានធ្វើឡើងដោយ ឬក្នុងនាមឧស្សាហកម្ម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

កម្ពុជា ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃចុះផ្សាយសេចក្ដីជូនដំណឹងអំពីការផុតសុពលភាពនៃវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ។ ពន្ធនោះអាចនៅមានប្រសិទ្ធភាពអនុវត្តបន្តទៀត ក្នុងខណៈពេលរង់ចាំលទ្ធផលសម្រេចនៃការត្រួតពិនិត្យឡើងវិញ ។

**មាត្រា ២៦ .-** ការត្រួតពិនិត្យឡើងវិញនៅក្នុងកាលៈទេសៈប្រែប្រួល

ក- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវត្រួតពិនិត្យឡើងវិញនូវភាពចាំបាច់ក្នុងការដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃជាបន្តទៀត ប្រសិនបើយល់ឃើញថាចាំបាច់ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនឬតាមសំណើជាលាយលក្ខណ៍អក្សររបស់ភាគីពាក់ព័ន្ធ ដែលភ្ជាប់មកជាមួយនូវព័ត៌មានវិជ្ជមានគ្រប់គ្រាន់តាមការតម្រូវឲ្យមានការត្រួតពិនិត្យឡើងវិញនោះ នៅក្នុងកំលុងពេលយ៉ាងតិច ១ (មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពន្ធស្ថាពរប្រឆាំងនឹងការលក់បង្ខូចថ្លៃ។ នៅពេលចាប់ផ្ដើមធ្វើការត្រួតពិនិត្យឡើងវិញ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយសេចក្ដីជូនដំណឹងក្នុងព្រឹត្តិបត្រព័ត៌មានផ្លូវការ ។

ខ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់ថាសំណើសុំត្រួតពិនិត្យឡើងវិញ ត្រូវមានភ្ជាប់មកជាមួយនូវព័ត៌មានគ្រប់គ្រាន់។ នៅពេលធ្វើការត្រួតពិនិត្យឡើងវិញអនុលោមតាមមាត្រានេះ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់ថាការដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃជាបន្តទៀតពិតជាមានការចាំបាច់សម្រាប់លុបបំបាត់ការលក់បង្ខូចថ្លៃ ឬការខូចខាតដែលទំនងជានឹងអាចកើតមានបន្តឬកើតឡើងវិញ ប្រសិនបើពន្ធនោះត្រូវបានលុបបំបាត់ ឬកែសម្រួល ឬក្នុងន័យទាំងពីរនេះ។ ប្រសិនជា គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រួតពិនិត្យឡើងវិញ ហើយរកឃើញថា ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃលែងមានភាពចាំបាច់តទៅទៀតនោះ ការដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃត្រូវតែបញ្ឈប់ជាបន្ទាន់ ។

គ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវកំណត់នូវនីតិវិធីសម្រាប់គណនាកម្រិតនៃការលក់បង្ខូចថ្លៃនីមួយៗចំពោះអ្នកនាំចេញ ឬផលិតករណាមួយនៅក្នុងប្រទេសនាំចេញពាក់ព័ន្ធដែលមិនបាននាំចេញនូវផលិតផលនោះមកព្រះរាជាណាចក្រកម្ពុជាក្នុងកំលុងពេលនៃការស៊ើបអង្កេត ប៉ុន្តែមានឯកសារ បញ្ជាក់ថា មានចេតនានាំចេញផលិតផលនោះមកព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៧ .-** រយៈពេលនិងការត្រួតពិនិត្យឡើងវិញលើការទទួលយកថ្លៃកែសម្រួល

បទប្បញ្ញត្តិនានានៃច្បាប់នេះទាក់ទងនឹងរយៈពេលនិងការត្រួតពិនិត្យឡើងវិញនៃវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ត្រូវបានយកមកអនុវត្តចំពោះការកំណត់រយៈពេលនិងការត្រួតពិនិត្យឡើងវិញលើការទទួលយកថ្លៃកែសម្រួល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ២៨ .-** កស្តុតាងនិងនីតិវិធី

ក- បទប្បញ្ញត្តិនានានៃច្បាប់នេះដែលទាក់ទងនឹងកស្តុតាងនិងនីតិវិធី ត្រូវបានយកមកអនុវត្ត ចំពោះការត្រួតពិនិត្យឡើងវិញស្របតាមការកំណត់ក្នុងជំពូកនេះ ។

ខ- ការត្រួតពិនិត្យឡើងវិញណាមួយត្រូវធ្វើឡើងឲ្យបានឆាប់រហ័ស និងត្រូវបញ្ចប់ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ គិតចាប់ពីថ្ងៃផ្តួចផ្តើមធ្វើការត្រួតពិនិត្យឡើងវិញ ។

## ផ្នែកទី ២
## ការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវ

**មាត្រា ២៩ .-** ការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវ

ការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវត្រូវកំណត់ដោយអនុក្រឹត្យ ដោយអនុលោមតាមច្បាប់ នេះ និងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីការឧបត្ថម្ភធន និង វិធានការពន្ធប៉ះប៉ូវ ។

## ផ្នែកទី ៣
## វិធានការការពារនិងនីតិវិធី

**មាត្រា ៣០ .-** ការខូចខាតធ្ងន់ធ្ងរនិងទំនាក់ទំនងហេតុផល

ក-សេចក្តីសម្រេចទាក់ទងនឹងកំណើននៃការនាំចូលផលិតផលក្រោមការស៊ើបអង្កេត ដែល បានបណ្តាល ឬកំពុងគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មកម្ពុជា ត្រូវផ្អែកលើការ វាយតម្លៃចំពោះកត្តាពាក់ព័ន្ធទាំងអស់ ដែលមានចរិតមិនលំអៀងនិងអាចវាស់វែងបាន ហើយដែល មានទំនាក់ទំនងទៅនឹងស្ថានភាពនៃឧស្សាហកម្មនោះ មានដូចជា ៖

១- អត្រា និងបរិមាណកំណើននៃការនាំចូលផលិតផលក្រោមការស៊ើបអង្កេតក្នុង លក្ខខណ្ឌដាច់ខាត ឬធៀបនឹងផលិតកម្មកម្ពុជាដែលផលិតនូវផលិតផលដូចគ្នា ឬផលិតផលដែល ប្រកួតប្រជែងដោយផ្ទាល់ ។

២- ចំណែកទីផ្សារក្នុងស្រុកដែលស្រូបយកដោយកំណើននៃការនាំចូលផលិតផល ក្រោមការស៊ើបអង្កេត ។

៣- ផលប៉ះពាល់ពីកំណើននៃការនាំចូលផលិតផលក្រោមការស៊ើបអង្កេតទៅលើ ឧស្សាហកម្មកម្ពុជាដែលអាចបញ្ជាក់បានដោយសូចនាករពាក់ព័ន្ធ រួមមានផលិតកម្ម សមត្ថភាពនៃ អត្ថប្រយោជន៍ ប្រែប្រួលកម្រិតលក់ ផលិតភាព ការចំណេញ និងការខាត ព្រមទាំងបរិមាណ ការងារ

៤- កត្តាផ្សេងៗទៀតក្រៅពីកំណើននៃការនាំចូលផលិតផលក្រោមការស៊ើបអង្កេត ហើយស្របពេលជាមួយគ្នានោះកំពុងបណ្តាល ឬកំពុងគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មកម្ពុជា ។

ខ-គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មអាចកំណត់ថា កំណើននៃការនាំចូលផលិតផលក្រោមការស៊ើបអង្កេតបានបណ្តាលឬកំពុងគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មកម្ពុជា លុះត្រាតែគណៈកម្មាធិការរកឃើញថា មានទំនាក់ទំនងហេតុផលរវាងកំណើននៃការនាំចូល និងការខូចខាតធ្ងន់ធ្ងរជាក់ស្តែង ឬការគំរាមគំហែងឲ្យខូចខាតធ្ងន់ធ្ងរ ។

គ-នៅពេលដែលមានកត្តាផ្សេងទៀតក្រៅពីកំណើននៃការនាំចូលផលិតផលក្រោមការស៊ើបអង្កេត ដែលស្របពេលជាមួយគ្នានោះបានបណ្តាលឬគំរាមកំហែងឱ្យមានការខូចខាត ការខូចខាតនោះមិនត្រូវបានចាត់ទុកថាបណ្តាលមកពីកំណើននៃការនាំចូលឡើយ ។

**មាត្រា ៣១ .-** ការគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរនិងទំនាក់ទំនងហេតុផល

ក- សេចក្តីសម្រេចនៃគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មស្តីពីការគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដែលបណ្តាលមកពីកំណើននៃការនាំចូល ត្រូវកំណត់ដោយផ្អែកលើភស្តុតាងនានា ដោយមិនត្រូវផ្អែកទៅលើការអះអាងដោយគ្មានភស្តុតាង ការប៉ាន់ស្មាន ឬការពាក់ព័ន្ធដោយប្រយោលនោះឡើយ ។

ខ-នៅក្នុងពេលពិចារណាអំពីកំណើននៃការនាំចូលដែលគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវវាយតម្លៃលើកត្តានានាដូចខាងក្រោម បន្ថែមពីលើកត្តាដែលមានចែងក្នុងមាត្រា ៣០ ចំណុច ក នៃច្បាប់នេះ ៖

១- សមត្ថភាពនៃការនាំចេញជាក់ស្តែងឬលទ្ធភាពនៃការនាំចេញរបស់ប្រទេសមួយ ឬបណ្តាប្រទេសម្ចាស់ផលិតកម្ម ឬប្រទេសប្រភពដើមផលិតផល ។

២-ការបង្កើនសារពើភណ្ឌណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងនៅក្នុងប្រទេសនាំចេញ ។

៣-លទ្ធភាពនៃការនាំចេញផលិតផលស្ថិតក្រោមការស៊ើបអង្កេតដែលបង្កើនបរិមាណនាំចូលមកក្នុងទីផ្សារកម្ពុជា ។

៤-កត្តាផ្សេងៗទៀតដែលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មចាត់ទុកថាមានការពាក់ព័ន្ធ ។

**មាត្រា ៣២ .-** ការផ្តួចផ្តើមនិងការស៊ើបអង្កេតអំពីវិធានការការពារ

ក- នៅពេលស៊ើបអង្កេតអំពីវិធានការការពារ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវអនុវត្តតាមគោលការណ៍និងនីតិវិធីទាំងឡាយដែលមានកំណត់នៅក្នុងមាត្រា ១៨ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ខ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់នីតិវិធីសម្រាប់ការផ្តួចផ្តើមអនុវត្ត និងបញ្ចប់ការស៊ើបអង្កេតអំពីវិធានការការពារ និងចេញសេចក្តីជូនដំណឹងជាសាធារណៈអំពីនីតិវិធីទាំងនោះ ។ អ្នកដាក់ពាក្យសុំស៊ើបអង្កេត អាចដកពាក្យវិញបាន មុនពេលផ្តួចផ្តើមស៊ើបអង្កេត ។

គ- មុនពេលការស៊ើបអង្កេតអំពីវិធានការការពារត្រូវបានបញ្ចប់ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវចាត់វិធានការការពារជាបណ្តោះអាសន្ន ដោយអនុលោមតាមសេចក្តីសម្រេចនិងការរកឃើញ និងមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាកំណើននៃការនាំចូលបានបណ្តាល ឬកំពុងគំរាមកំហែងឲ្យមានការខូចខាតធ្ងន់ធ្ងរ និងបញ្ជាក់ថាការពន្យារពេលស៊ើបអង្កេតដើម្បីឈានទៅធ្វើសេចក្តីសម្រេចអាចបណ្តាលឲ្យមានការខូចខាតដែលពិបាកនឹងជួសជុលបាន ។

ឃ- វិធានការការពារនិងនីតិវិធីនៃការអនុវត្ត ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៣ .-** សេចក្តីកំណត់អំពីការខូចខាតធ្ងន់ធ្ងរឬការគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរ និងទំនាក់ទំនងហេតុផល

ក- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវផ្អែកលើភស្តុតាងជាក់លាក់ដែលទទួលបានពីការស៊ើបអង្កេត សម្រាប់កំណត់ថាកំណើននៃការនាំចូលផលិតផលក្រោមការស៊ើបអង្កេត ពិតជាបានបណ្តាលឬគំរាមកំហែងឲ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មកម្ពុជា ដោយអនុលោមតាមបញ្ញត្តិនានានៃច្បាប់នេះ ។

ខ- បន្ទាប់ពីកំណត់បានអំពីលទ្ធផល ទោះបីជាវិជ្ជមានក្តីឬអវិជ្ជមានក្តី ចំពោះការខូចខាតធ្ងន់ធ្ងរឬការគំរាមកំហែងឲ្យមានការខូចខាតធ្ងន់ធ្ងរ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវចុះផ្សាយជាបន្ទាន់នូវសេចក្តីជូនដំណឹងអំពីលទ្ធផលនោះនៅក្នុងព្រឹត្តិបត្រព័ត៌មានផ្លូវការ ។ ខ្លឹមសារនៃសេចក្តីជូនដំណឹងត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវនៃសេចក្តីជូនដំណឹងស្តីពីការស៊ើបអង្កេតអំពីវិធានការការពារ ។

គ- រាជរដ្ឋាភិបាលត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គការពាណិជ្ជកម្មពិភពលោក ប្រសិនបើមានការកំណត់ថាកំណើននៃការនាំចូលបានបណ្តាល ឬគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មកម្ពុជា ។

**មាត្រា ៣៤ .-** គោលការណ៍ទូទៅនៃវិធានការការពារជាស្ថាពរ

ក- ក្នុងករណីគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មកំណត់បានថា កំណើនផលិតផលនាំចូល ស្ថិតក្រោមការស៊ើបអង្កេត កំពុងមានបរិមាណកើនឡើងហើយស្ថិតក្នុងស្ថានភាពបណ្តាល ឬគំរាមកំហែងឲ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មកម្ពុជា ដែលមិនអាចប៉ាន់ស្មានលទ្ធផលទុកមុនបានក្នុងនាមសមាជិក ដែលស្ថិតនៅក្រោមកាតព្វកិច្ចនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ និងដើម្បីការពារផលប្រយោជន៍សាធារណៈ គណៈកម្មាធិការជាតិឧបាស្រ័យ

ROYAUME DE CAMBODGE • LE MINISTRE DU PALAIS ROYAL •

ពាណិជ្ជកម្ម ត្រូវលើកយោបល់ជូនរាជរដ្ឋាភិបាលដើម្បីអនុវត្តវិធានការការពារជាស្ថាពរ ។ វិធានការការពារជាស្ថាពរដែលបានលើកឡើងរួមមានការបង្កើនអត្រាពន្ធគយ ឲ្យលើសពីអត្រាពន្ធដែលបានចង ឬធ្វើការកំណត់បរិមាណនាំចូល ។

ខ- រយៈពេលនិងកម្រិតនៃវិធានការការពារជាស្ថាពរណាមួយ មិនត្រូវហួសពីភាពចាំបាច់ដើម្បីការពារមិនឱ្យកើតមាន ឬកែលម្អការខូចខាតធ្ងន់ធ្ងរនិងកែតម្រូវស្ថានការណ៍ឡើងវិញឡើយ ។

គ- នៅក្នុងការសម្រេចលើកយោបល់ជូនរាជរដ្ឋាភិបាលឲ្យចាត់វិធានការការពារជាស្ថាពរ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវពិចារណាថា ៖

១- សមាជិកអង្គការពាណិជ្ជកម្មពិភពលោកផ្សេងទៀត ដែលទទួលរងនូវផលប៉ះពាល់អវិជ្ជមានពីការអនុវត្តវិធានការការពារលើផលប្រយោជន៍ពាណិជ្ជកម្មរបស់ប្រទេសសមាជិកនោះ អាចនឹងស្នើសុំឲ្យមានសំណងនៃការខូចខាតពីកម្ពុជាវិញ តាមរយៈការទាមទារឲ្យកម្ពុជាបើកច្រកចូលទីផ្សារដែលមានភាពអនុគ្រោះច្រើនជាងមុនសម្រាប់ផលិតផលនាំចេញប្រភេទផ្សេងទៀតរបស់ខ្លួន ឬ

២- ក្នុងករណីដែលកម្ពុជា មិនព្រមព្រៀងក្នុងការផ្តល់សំណងដូចបានបញ្ជាក់ក្នុងកថាខណ្ឌទី ១ ទេ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវថ្លឹងថ្លែងពីផលចំណេញនិងការខាតបង់ បណ្តាលមកពីវិធានការតបតដែលសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនោះ អាចនឹងព្យួរសម្បទានដែលសមមូលគ្នាទៅ នឹងសម្បទានដែលសមាជិកនោះ បានផ្តល់ឱ្យកម្ពុជាក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម ឆ្នាំ ១៩៩៤ ប្រសិនបើការព្យួរនោះមិនត្រូវបានជំទាស់ដោយក្រុមប្រឹក្សាពាណិជ្ជកម្មទំនិញរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ សិទ្ធិព្យួរសម្បទានដែលអាចត្រូវបានអនុវត្តដោយប្រទេសជាសមាជិកនោះ នឹងមិនត្រូវបានយកមកអនុវត្តឡើយក្នុងរយៈពេល ៣(បី) ឆ្នាំដំបូង ដែលវិធានការការពារកំពុងស្ថិតនៅជាធរមាន ប្រសិនបើវិធានការនោះត្រូវបានធ្វើឡើងក្រោមមូលហេតុនៃការកើនឡើងដាច់ខាតនៃការនាំចូល ។

ឃ- បន្ទាប់ពីផ្តល់អនុសាសន៍ស្តីពីការសម្រេចអនុវត្តវិធានការការពារជាស្ថាពរ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវចុះផ្សាយសេចក្តីជូនដំណឹងស្តីពីការអនុវត្តវិធានការការពារជាស្ថាពរ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃសេចក្តីជូនដំណឹងពីការស៊ើបអង្កេតអំពីវិធានការការពារ ។

**មាត្រា ៣៥ .-** សេចក្តីជូនដំណឹង និងការពិគ្រោះយោបល់ជាមួយសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

ក- រាជរដ្ឋាភិបាល ត្រូវជូនដំណឹងដល់អង្គការពាណិជ្ជកម្មពិភពលោក បន្ទាប់ពីបានសម្រេចលើសំណើសុំអនុវត្តវិធានការការពារជាស្ថាពរ អំពី ៖

១- ភស្តុតាងនៃការខូចខាតធ្ងន់ធ្ងរឬការគំរាមកំហែងនាំឱ្យមានការខូចខាតធ្ងន់ធ្ងរដែលបណ្តាលមកពីកំណើននៃការនាំចូល

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

២- សេចក្តីពណ៌នាពិស្តារអំពីផលិតផលក្រោមការស៊ើបអង្កេត ទម្រង់ កម្រិត និងរយៈពេលនៃវិធានការដែលស្នើឡើង

៣- កាលបរិច្ឆេទដែលបានស្នើឡើងសម្រាប់អនុវត្តវិធានការនិងកាលវិភាគស្នើឡើងសម្រាប់ដកចេញជាបណ្តើរៗ នូវវិធានការនោះ ប្រសិនបើមាន ។

ខ- មុនពេលអនុវត្តវិធានការការពារជាស្ថាពរ រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់ការពិគ្រោះយោបល់ជាមួយបណ្តាប្រទេសសមាជិកដែលមានផលប្រយោជន៍ច្រើន ក្នុងនាមជាអ្នកនាំចេញផលិតផលក្រោមការស៊ើបអង្កេត ក្នុងគោលបំណងត្រួតពិនិត្យឡើងវិញនូវព័ត៌មាននានាដែលត្រូវជូនដំណឹងទៅគណៈកម្មាធិការស្តីពីការការពាររបស់អង្គការពាណិជ្ជកម្មពិភពលោក អំពីការរកឃើញនូវការខូចខាតធ្ងន់ធ្ងរឬការគំរាមកំហែងឲ្យមានការខូចខាតធ្ងន់ធ្ងរបណ្តាលមកពីកំណើននៃការនាំចូល និងអំពីវិធានការការពារដែលដាក់ចេញ ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្តល់ឱកាសសម្រាប់ការផ្លាស់ប្តូរយោបល់គ្នាអំពីវិធានការដើម្បីទទួលបាននូវការយោគយល់គ្នាអំពីវិធីសាស្ត្រនានាសំដៅសម្រេចបាននូវគោលដៅដូចមានចែងនៅក្នុងកថាខណ្ឌ "គ" នៃមាត្រានេះ ។

គ- នៅពេលអនុវត្តវិធានការការពារជាស្ថាពរ រាជរដ្ឋាភិបាលកម្ពុជាត្រូវខិតខំរក្សាកម្រិតសមមូលនៃសម្បទាននិងកាតព្វកិច្ចផ្សេងៗដែលស្ថិតនៅជាធរមានក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ ១៩៩៤ រវាងកម្ពុជានិងប្រទេសសមាជិកនាំចេញ ដែលអាចទទួលរងផលប៉ះពាល់ពីការអនុវត្តវិធានការនោះ ។

ឃ- ការរក្សាកម្រិតសមមូលនៃសម្បទាននិងកាតព្វកិច្ចផ្សេងៗនៃកិច្ចព្រមព្រៀងរវាងកម្ពុជាជាមួយ បណ្តាប្រទេសសមាជិកដែលរងផលប៉ះពាល់ ត្រូវបានធ្វើឡើងតាមរយៈការពិគ្រោះយោបល់លើការទូទាត់សំណងពាណិជ្ជកម្ម ដូចជាការបើកច្រកចូលទីផ្សារសម្រាប់ផលិតផលផ្សេង ដោយសារមានផលប៉ះពាល់អវិជ្ជមានបណ្តាលមកពីការដាក់វិធានការការពារជាស្ថាពរទៅលើពាណិជ្ជកម្មរបស់បណ្តាប្រទេសសមាជិកទាំងនោះ ។

ង- រាជរដ្ឋាភិបាលត្រូវជូនដំណឹងដល់អង្គការពាណិជ្ជកម្មពិភពលោក អំពីលទ្ធផលនៃការពិគ្រោះយោបល់ រួមទាំងការផ្តល់សំណងខូចខាតផ្សេងៗ ។

**មាត្រា ៣៦ .-** ទម្រង់និងការអនុវត្តវិធានការការពារជាស្ថាពរ

ក- វិធានការការពារជាស្ថាពរត្រូវធ្វើឡើងក្នុងទម្រង់ជាការបង្កើនពន្ធគយ ឬជាការកំណត់កូតាលើការនាំចូល ។ ការបង្កើនពន្ធគយអាចធ្វើឡើងក្នុងទម្រង់ជាការដាក់អត្រាពន្ធគយកូតាកំណត់ណាមួយដែលអត្រាពន្ធគយខ្ពស់ជាងធម្មតានោះ ត្រូវកំណត់លើបរិមាណនាំចូលប្រចាំឆ្នាំ ។

ខ- វិធានការការពារជាស្ថាពរត្រូវអនុវត្តចំពោះការនាំចូលផលិតផលក្រោមការស៊ើបអង្កេតទាំងអស់ ដោយមិនគិតពីប្រភពនាំចូល ឬកាលបរិច្ឆេទនាំចូលមុន ឬក្រោយវិធានការនេះចូលជាធរមានឡើយ ។

គ- រដ្ឋបាលគយត្រូវទទួលខុសត្រូវប្រមូលប្រាក់ដែលទទួលបានពីការអនុវត្តវិធានការការពារជាស្ថាពរ ក្នុងទម្រង់ជាការបង្កើនពន្ធគយ ។ ក្រសួងពាណិជ្ជកម្មត្រូវទទួលខុសត្រូវផ្នែករដ្ឋបាលលើនីតិវិធីក្នុងការបែងចែកបរិមាណកំណត់ក្រោមវិធានការការពារជាស្ថាពរ ដែលអនុវត្តក្នុងទម្រង់ជាការកម្រិតលើបរិមាណ និងអត្រាពន្ធគយកូតា ។

**មាត្រា ៣៧ .-** ការមិនអនុវត្តវិធានការការពារជាស្ថាពរចំពោះប្រទេសកំពុងអភិវឌ្ឍមួយចំនួន

ក- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម មិនត្រូវអនុវត្តវិធានការការពារជាស្ថាពរចំពោះផលិតផលនាំចូលស្ថិតក្រោមការស៊ើបអង្កេតមានប្រភពដើមចេញមកពីប្រទេសកំពុងអភិវឌ្ឍជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកណាមួយ ដែលតម្លៃទំនិញនាំចូលនោះមានកម្រិតតិចជាងបីភាគរយ (៣%) នៃតម្លៃនាំចូលសរុបនៃផលិតផលក្រោមការស៊ើបអង្កេតមកកម្ពុជា ។

ខ- ទោះបីជាការនាំចូលពីប្រទេសសមាជិកកំពុងអភិវឌ្ឍនីមួយៗមានតម្លៃតិចជាង ៣%(បី) ភាគរយនៃតម្លៃសរុបនៃផលិតផលនាំចូលស្ថិតក្រោមការស៊ើបអង្កេតក៏ដោយ តែបរិមាណសរុបនៃទំនិញនាំចូលពីបណ្តាប្រទេសកំពុងអភិវឌ្ឍទាំងនោះមកកម្ពុជា មានតម្លៃធំជាង ៩ %(ប្រាំបួន)ភាគរយនៃតម្លៃសរុបនៃផលិតផលនាំចូលស្ថិតក្រោមការស៊ើបអង្កេត គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវអនុវត្តវិធានការការពារជាស្ថាពរចំពោះការនាំចូលពីបណ្តាប្រទេសសមាជិកកំពុងអភិវឌ្ឍទាំងនោះ ។

គ- រាជរដ្ឋាភិបាលត្រូវជូនដំណឹងពីការមិនអនុវត្តវិធានការការពារជាស្ថាពរ ចំពោះផលិតផលនាំចូលដែលមានប្រភពពីប្រទេសសមាជិកកំពុងអភិវឌ្ឍទៅអង្គការពាណិជ្ជកម្មពិភពលោក ។

**មាត្រា ៣៨ .-** រយៈពេលនៃការអនុវត្តវិធានការការពារជាស្ថាពរ

ក- វិធានការការពារជាស្ថាពរត្រូវបានអនុវត្តក្នុងរយៈពេលកំណត់មួយដែលមិនឱ្យលើស ៤ (បួន)ឆ្នាំ លើកលែងតែមានការពន្យារពេល ដោយអនុលោមតាមច្បាប់នេះ ។

ខ- រយៈពេលសរុបនៃការអនុវត្តវិធានការការពារជាស្ថាពរ រួមទាំងរយៈពេលអនុវត្តដំបូង និងរយៈពេលអនុវត្តបន្តណាមួយមិនត្រូវឱ្យលើសរយៈពេល ១០ (ដប់) ឆ្នាំ ឡើយ។

**មាត្រា៣៩ .-** ការដកចេញជាបណ្តើរៗនូវវិធានការការពារជាស្ថាពរ

វិធានការការពារជាស្ថាពរដែលមានរយៈពេលអនុវត្តលើសពី ១(មួយ)ឆ្នាំ អាចត្រូវបានដកចេញជាបណ្តើរៗ តាមកម្មវិធីជាក់លាក់ក្នុងកំលុងពេលអនុវត្តវិធានការ ដោយអនុលោមតាមកាលវិភាគដែលបានបោះពុម្ពផ្សាយនៅក្នុងសេចក្តីជូនដំណឹងអំពីការអនុវត្តវិធានការការពារជាស្ថាពររបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ។

**មាត្រា ៤០ .-** ការត្រួតពិនិត្យឡើងវិញនូវវិធានការការពារជាស្ថាពរ

ក- ក្នុងករណីដែលរយៈពេលនៃការអនុវត្តវិធានការការពារជាស្ថាពរលើសពី ៣ (បី) ឆ្នាំ គណៈ-កម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវស្ថានភាពទូទៅនៃការអនុវត្តវិធានការការពារជាស្ថាពរ មិនឱ្យយឺតជាងពាក់កណ្តាលរយៈពេលនៃការអនុវត្តវិធានការការពារជាស្ថាពរឡើយ ។ ការត្រួតពិនិត្យឡើងវិញ ត្រូវពិនិត្យមើលប្រសិទ្ធភាពនៃការដាក់អនុវត្តវិធានការការពារជាស្ថាពរចំពោះឧស្សាហកម្មកម្ពុជា និងវឌ្ឍនភាពនៃការអនុវត្តផែនការកែតម្រូវរបស់ឧស្សាហកម្មកម្ពុជា ។ លទ្ធផលនៃការត្រួតពិនិត្យឡើងវិញ ត្រូវចុះផ្សាយនៅក្នុងព្រឹត្តិបត្រព័ត៌មានផ្លូវការរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ។ ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យឡើងវិញនេះ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវសម្រេចរក្សាទុក ឬដកចេញទាំងស្រុងនូវវិធានការការពារជាស្ថាពរនោះ ឬក៏ត្រូវបង្កើនល្បឿននៃការដកចេញនូវវិធានការការពារជាស្ថាពរជាបណ្តើរៗ ។

ខ- សេចក្តីជូនដំណឹងសង្ខេបស្តីពីលទ្ធផលនៃការត្រួតពិនិត្យឡើងវិញទាក់ទងនឹងការរក្សាទុក ការដកចេញជាបណ្តើរៗ ឬការដកចេញទាំងស្រុងនូវវិធានការការពារជាស្ថាពរ ត្រូវចុះផ្សាយនៅក្នុងព្រឹត្តិបត្រព័ត៌មានផ្លូវការរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ។ ខ្លឹមសារនៃសេចក្តីជូនដំណឹងត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវនៃសេចក្តីជូនដំណឹងអំពីការស៊ើបអង្កេតស្តីពីវិធានការការពារ ។

គ- រាជរដ្ឋាភិបាលត្រូវជូនដំណឹងទៅអង្គការពាណិជ្ជកម្មពិភពលោក អំពីលទ្ធផលនៃការត្រួតពិនិត្យនេះ រួមទាំងការដកចេញ ឬការកែសម្រួលណាមួយលើវិធានការការពារជាស្ថាពរ ។

**មាត្រា ៤១ .-** ការបន្តអនុវត្តនូវវិធានការការពារជាស្ថាពរ

ក- ឧស្សាហកម្មកម្ពុជាអាចស្នើសុំជាលាយលក្ខណ៍អក្សរនៅក្នុងរយៈពេលមិនតិចជាង ៦ (ប្រាំមួយ) ខែ មុនផុតរយៈពេលអនុវត្តវិធានការការពារជាស្ថាពរដំបូង ទៅគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ឲ្យបន្តអនុវត្តនូវវិធានការការពារជាស្ថាពរដំបូង ដោយភ្ជាប់ជាមួយនូវភស្តុតាងដែលបញ្ជាក់ថាឧស្សាហកម្មរបស់ខ្លួនកំពុងអនុវត្តផែនការកែសម្រួលជាបណ្តើរៗហើយ ។

បន្ទាប់ពីទទួលបានសំណើពីឧស្សាហកម្មកម្ពុជា ឬនៅពេលចាប់អនុវត្តបន្តនូវវិធានការដែលបានផ្តួចផ្តើម គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវធ្វើការស៊ើបអង្កេតឲ្យបានច្បាស់លាស់ដើម្បីធានាថាការអនុវត្តបន្តនូវវិធានការនេះមានលក្ខណៈត្រឹមត្រូវ ។ នីតិវិធីនានាសម្រាប់អនុវត្តវិធានការដំបូង ដែលមានចែងក្នុងច្បាប់នេះ ត្រូវយកមកអនុវត្តសម្រាប់ការស៊ើបអង្កេតនិងការចេញសេចក្តីសម្រេច ។ វិធានការការពារអាចត្រូវបានបន្តអនុវត្តតែម្តងគត់សម្រាប់រយៈពេលមិនឱ្យលើសពី ៦ (ប្រាំមួយ) ឆ្នាំឡើយ ។

ខ- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម អាចបន្តអនុវត្តវិធានការការពារជាស្ថាពរ តែក្នុងករណីដែលបានស៊ើបអង្កេតដូចមានចែងក្នុងកថាខណ្ឌ "ក" ខាងលើ ហើយគណៈកម្មាធិការអាចកំណត់បានថាវិធានការការពារជាស្ថាពរនៅតែត្រូវការជាចាំបាច់ដើម្បីបង្ការ ឬកែលម្អការខូចខាតធ្ងន់ធ្ងរ និងកើតបាន និងមានភស្តុតាងបញ្ជាក់ថាឧស្សាហកម្មកម្ពុជាកំពុងតែធ្វើការកែសម្រួល ។

គ- វិធានការការពារជាស្ថាពរដែលត្រូវបានអនុវត្តបន្ត មិនត្រូវមានលក្ខណៈតឹងតែងជាងវិធានការដែលអនុវត្តនៅចុងកាលបរិច្ឆេទនៃរយៈពេលអនុវត្តវិធានការដំបូងនោះឡើយ ។ នៅក្នុងរយៈពេលបន្តអនុវត្តវិធានការការពារជាស្ថាពរ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មត្រូវតែបន្ធូរដកចេញជាបណ្តើរៗនូវវិធានការនោះ ដោយអនុលោមតាមកម្មវិធីកែសម្រួលដែលមានបោះពុម្ពផ្សាយនៅក្នុងសេចក្តីជូនដំណឹងស្តីពីការអនុវត្តវិធានការការពារជាស្ថាពរ ។ ខ្លឹមសារនៃសេចក្តីជូនដំណឹង ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវនៃសេចក្តីជូនដំណឹងអំពីការស៊ើបអង្កេតស្តីពីវិធានការការពារ ។

ឃ- នៅក្នុងការបន្តអនុវត្តនូវវិធានការការពារជាស្ថាពរ រាជរដ្ឋាភិបាលត្រូវរក្សាកម្រិតសមមូលនៃសម្បទាន និងកាតព្វកិច្ចនានាដែលបានផ្តល់ឱ្យក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម ឆ្នាំ ១៩៩៤ រវាងកម្ពុជានិងប្រទេសសមាជិកនាំចេញដែលអាចទទួលរងនូវផលប៉ះពាល់ពីការអនុវត្តវិធានការទាំងនេះ ។

ង- លក្ខខណ្ឌតម្រូវទាក់ទងនឹងការជូនដំណឹងទៅអង្គការពាណិជ្ជកម្មពិភពលោកនិងការពិគ្រោះយោបល់ជាមួយប្រទេសសមាជិកនាំចេញដែលទទួលរងនូវផលប៉ះពាល់ពីការអនុវត្តវិធានការដូចមានចែងក្នុងច្បាប់នេះ ត្រូវយកមកអនុវត្តទាំងស្រុង ចំពោះការអនុវត្តបន្តនូវវិធានការការពារជាស្ថាពរនេះ ។

**មាត្រា ៤២ .-** ការអនុវត្តឡើងវិញនូវវិធានការការពារជាស្ថាពរ

ក- គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មមិនចាំបាច់យកវិធានការការពារថ្មីណាមួយមកអនុវត្តម្តងទៀតចំពោះផលិតផលនាំចូលដែលស្ថិតក្រោមវិធានការការពារជាស្ថាពរ ដែលបានអនុវត្តកន្លងមកមុនរយៈពេល ២(ពីរ)ឆ្នាំ គិតចាប់ពីវិធានការការពារជាស្ថាពរ លើកដំបូងបានអនុវត្តចប់នោះឡើយ ។ ក្នុងកាលៈទេសៈដែលវិធានការការពារជាស្ថាពរលើកដំបូងបានអនុវត្តក្នុងរយៈពេលយូរជាង ៤(បួន) ឆ្នាំ គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវរង់ចាំយ៉ាងតិចពាក់កណ្តាលនៃរយៈពេលអនុវត្តវិធានការការពារជាស្ថាពរលើកដំបូងកន្លងផុត ទើបអាចអនុវត្តវិធានការថ្មីបាន ។

ខ- វិធានការការពារដែលមានរយៈពេល ១៨០ (មួយរយប៉ែតសិប)ថ្ងៃ ឬតិចជាងនេះ ត្រូវបានយកមកអនុវត្តឡើងវិញចំពោះផលិតផលនាំចូលស្ថិតក្រោមការស៊ើបអង្កេត ដែលធ្លាប់ត្រូវបានអនុវត្តវិធានការការពារដំបូង ប្រសិនបើ ៖

១- រយៈពេលយ៉ាងតិច ១(មួយ) ឆ្នាំ បានកន្លងផុតទៅ គិតចាប់តាំងពីថ្ងៃដែលបានដាក់ចេញនូវវិធានការការពារលើកដំបូងទៅលើផលិតផលនាំចូលនោះ និង

២- វិធានការការពារមិនទាន់បានអនុវត្តលើផលិតផលនាំចូល លើសពីពីរដងក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្តវិធានការការពារថ្មីចូលជាស្ថាពរ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ៤
# បណ្តឹងតាមផ្លូវតុលាការ

**មាត្រា ៤៣ .-** បណ្តឹងតាមផ្លូវតុលាការ

ក- ភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងការស៊ើបអង្កេតឬក្នុងនីតិវិធីសងប្រាក់ពន្ធមកវិញ ឬក្នុងការត្រួតពិនិត្យឡើងវិញធ្វើឡើងដោយគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម តាមរយៈការផ្តល់ព័ត៌មាន ឬជាលាយលក្ខណ៍អក្សរ ឬចូលរួមនៅក្នុងសវនាការសាធារណៈ អាចដាក់ពាក្យប្តឹងទៅតុលាការមានសមត្ថកិច្ចឱ្យពិនិត្យឡើងវិញនូវសកម្មភាពទាំងឡាយរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចចុងក្រោយ ការត្រួតពិនិត្យឡើងវិញលើសេចក្តីសម្រេចនានា និងការធ្វើសេចក្តីសម្រេចពីការសងប្រាក់ពន្ធមកវិញ ។

ខ- បណ្តឹងដូចមានចែងក្នុងកថាខណ្ឌ "ក" ខាងលើ ត្រូវធ្វើមិនឱ្យយឺតជាង ៣០ (សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញផ្សាយសេចក្តីសម្រេចនោះក្នុងព្រឹត្តិបត្រព័ត៌មានផ្លូវការរបស់គណៈ-កម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មឡើយ ។

គ- ក្នុងករណីដែលវិធានការឧបាស្រ័យពាណិជ្ជកម្មកំពុងត្រូវបានត្រួតពិនិត្យឡើងវិញតាមផ្លូវតុលាការ រដ្ឋបាលគយ ត្រូវផ្អាកការប្រមូលពន្ធឧបាស្រ័យពាណិជ្ជកម្មនៅតាមមាត់ច្រកនាំចូលទំនិញពាក់ព័ន្ធនឹងបណ្តឹង ប្រសិនជាអ្នកនាំចូលបានផ្តល់នូវនិមុត្តិធានា តាមរយៈការតម្កល់សាច់ប្រាក់ ឬប្រាក់ធានាដោយអនុលោមតាមច្បាប់គយ ដែលមានតម្លៃសមមូលទៅនឹងប្រាក់ពន្ធនោះ ។ ពន្ធឧបាស្រ័យពាណិជ្ជកម្មនៅមាត់ច្រកនាំចូលទាំងនោះ ត្រូវបានប្រមូលដោយអនុលោមតាមសេចក្តីសម្រេចចុងក្រោយរបស់តុលាការ ។

# ជំពូកទី ៥
# ទោសប្បញ្ញត្តិ

**មាត្រា ៤៤ .-**

ក- ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ខ- ប្រសិនបើគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មពិនិត្យឃើញថាព័ត៌មានទាំងឡាយដែលបានផ្តល់មកសម្រាប់គាំទ្រឲ្យមានការស៊ើបអង្កេត ការអនុវត្តវិធានការប្រឆាំងការលក់បង្ខូចថ្លៃ ឬវិធានការការពារ ត្រូវបានផ្តល់ដោយក្លែងបន្លំនោះ វិធានការប្រឆាំងការលក់បង្ខូចថ្លៃ ឬវិធានការការពារនឹងត្រូវបានដកចេញវិញ ឬការស៊ើបអង្កេតនឹងត្រូវបានបញ្ឈប់ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៦

# អវសានប្បញ្ញត្តិ

**មាត្រា ៤៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម.១១១៧.០៤០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ហត្ថលេខា**
**ប៉ាន សូរស័ក្តិ**

លេខ:១០៣៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**